មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights

# របាយការណ៍

## សិក្ខាសាលាស្តីពី

## "ទាំងអស់គ្នាដើម្បីអាជីវកម្ម និងសិទ្ធិមនុស្ស"

### ២៨ ឧសភា ២០១០ ភោជនីយដ្ឋាន បៃតង —— ភ្នំពេញ, ព្រះរាជាណាចក្រកម្ពុជា

**សេចក្តីផ្តើម**

នៅថ្ងៃទី ២៨ ឧសភា ២០១០, មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជាបានរៀបចំសិក្ខាសាលាមួយ ដែលជាផ្នែកមួយ នៃគំរោងអាជីវកម្ម និង សិទ្ធិមនុស្ស។ សិក្ខាសាលានេះគឺជាផ្នែកមួយនៃសិក្ខាសាលាបន្តបន្ទាប់គ្នា ស្តីពី "ទាំងអស់គ្នាដើម្បីអាជីវកម្ម និង សិទ្ធិមនុស្ស" មានគោលដៅទៅដល់អ្នកតំណាងនៃវិស័យឯកជននៅកម្ពុជា។ សិក្ខាសាលាដែលមានការចូលរួមដោយសមាជិកនៃសហគមន៍អាជីវកម្មកម្ពុជា ត្រូវបានបង្កើតឡើងដើម្បីបង្ហាញ អ្នកដែលមានការពាក់ព័ន្ធទៅនឹងអាជីវកម្ម និងសិទ្ធិមនុស្ស និង បង្កើនការយល់ដឹងរបស់ពួកគេនៃសិទ្ធិមនុស្ស តាមរយៈការធ្វើបទបង្ហាញពី CCHR និងវាគ្មិន។ តាមរយៈសិក្ខាសាលា ចំនួននៃករណីសិក្សាត្រូវបានគេបង្ហាញ និងការពិភាក្សាជាក្រុមដែលទាក់ទងនឹងវិធី ដែលសកម្មភាពអាជីវកម្មអាចមានផលប៉ះពាល់ដល់សិទ្ធិមនុស្ស។ សកម្មភាពទាំងនោះត្រូវបានគេអនុវត្តជាមួយនឹងគោលបំណងនៃការផ្តួចផ្តើមនៃដំណើរការនៃការ បង្ករអោយមានអត្ថន័យពេញលេញនៃសិទ្ធិមនុស្ស ដោយផ្អែកលើកិច្ចពិភាក្សារវាង អាជីវកម្មកម្ពុជា និង សង្គមស៊ីវិល។ លើសពីនេះទៀត សិក្ខាសាលានេះបានបង្ហាញឱកាសយ៉ាងសំខាន់ក្នុងការពិភាក្សាលើ សេចក្តីថ្លែងការណ៍ស្តីពីគោលការណ៍គោរពសិទ្ធិមនុស្ស (SOP), ជាកិច្ចព្រមព្រៀងដែលមិនចងកាតព្វកិច្ច មាន ១០ គោលការណ៍សំខាន់ មានទិសដៅជំរុញអោយអាជីវកម្មប្រមូលផ្តុំជាមួយនឹងកាតព្វកិច្ចគោរពសិទ្ធិមនុស្សរបស់ពួកគេ។ វាគ្មិនក្នុងកម្មវិធី មានលោក វង្ស សុវណ្ណ, ប្រធាន សហព័ន្ធសហជីពការងារកម្មករកម្ពុជា (CWLFU) និង លោកយ៉េង វីរៈ, ប្រធានមជ្ឈមណ្ឌលអប់រំច្បាប់សំរាប់សហគមន៍ CLEC។

របាយការណ៍ខាងក្រោម នឹងពន្យល់ពីខ្លឹមសារសំខាន់នៃសិក្ខាសាលានេះ និងសង្ខេបពីបទពិសោធន៍ និង ការជជែកវែកញែកដែលបានលើឡើងក្នុងកិច្ចប្រជុំពិភាក្សាគ្នានេះ។ របាយការណ៍នេះ ធ្វើឡើងដើម្បីត្រួតពិនិត្យ តាមដានពីសិក្ខាសាលា និងសង្ឃឹមថាអាចជួយជាគំនិតដល់អ្នកចូលរួម និងអាចអោយពួកគេគិតអំពីជំហានបន្ត បន្ទាប់ថា គួរធ្វើយ៉ាងដូចម្តេច ទាក់ទងទៅនឹងសិទ្ធិមនុស្សក្នុងអាជីវកម្ម។

## សាវតារ:

សិក្ខាសិលានេះជាសិក្ខាសាលាលើកទីប្រាំមួយតាមលំដាប់លំដោយនៃសិក្ខាសាលាអាជីវកម្មនិង សិទ្ធិមនុស្ស របស់ CCHR/OHCHR សំរាប់ក្រុមដែលពាក់ព័ន្ធក្នុងវិស័យឯកជននៅកម្ពុជា។ សិក្ខាសាលាលើកទីមួយ ធ្វើឡើងសំរាប់អង្គការក្រៅរដ្ឋាភិបាល និង តំណាងសង្គមស៊ីវិលក្នុងខែ វិច្ឆិកា ឆ្នាំ ២០០៩ គឺទទួលបានជោគជ័យ និង នាំទៅរកការកើនឡើងនៃការចូលរួមដើម្បីស្ថាបនាលើអាជីវកម្ម និង សិទ្ធិមនុស្សរវាងស្ថាប័នក្រៅរដ្ឋាភិបាល។ សិក្ខាសាលាលើកទីពីរផ្តួចផ្តើមអោយមានការចាប់ផ្តើមដំណើរការ នាំអោយមានកិច្ចពិភាក្សារវាង អាជីវកម្មកម្ពុជា និង សង្គមស៊ីវិល ដែលជាគោលបំណងស្នូលនៃគំរោងនេះ។

សិក្ខាសាលាលើកទីបី ទីបួន ទីប្រាំ និងទីប្រាំមួយ ជាសិក្ខាសាលាត១គ្នា និង មានទិសដៅលើកកំពស់ ការយល់ដឹង សិទ្ធិមនុស្សតាមរយៈ សេចក្តីថ្លែងការណ៏នៃគោលការណ៏ ស្តីពីអាជីវកម្ម និង សិទ្ធិមនុស្ស (SOP)។

សិក្ខាសាលាមុននេះ បានបង្ហាញពីជំហានដំបូងក្នុងការបង្កើតអោយមាន បរិយាកាសនៃការ សហការដែលមិនប្រឈមមុខដាក់គ្នា លើអាជីវកម្ម និង សិទ្ធិមនុស្សរវាងក្រុមដែលពាក់ព័ន្ធ ក្នុងវិស័យឯកជន នៅកម្ពុជា។ វាគ្មិនដែលជាតំណាងមកពីសហជីពការងារ និង NGOs នៅសិក្ខាសាលាទាំងនេះ បានជួយបង្កើនការ យល់ដឹងក្នុងចំណោមអ្នកតំណាងអាជីវកម្ម ក្នុងការចូលរួម ដែលអាជីវកម្មអាចមានការ ប៉ះពាល់ដល់សិទ្ធិមនុស្ស ក្នុងប្រតិបត្តិការរបស់ពួកគេ។ តាមរយៈការពិភាក្សានៅក្នុងសិក្ខាសាលា, សេចក្តីថ្លែងការណ៏នៃ គោលការណ៏ស្តីពី អាជីវកម្ម និង សិទ្ធិមនុស្សនៅព្រះរាជាណាចក្រកម្ពុជា ត្រូវបានគេតាក់តែងឡើង (SOP)។

## គោលបំណងរបស់សិក្ខាសាលា

សង្ឃឹមថាសិក្ខាសាលានេះនិងអាចៈ

- លើកកំពស់ការយល់ដឹងអំពីអ្វីជាសិទ្ធិមនុស្ស និងអំពីវិធីដែលសិទ្ធិមនុស្សមានការពាក់ព័ន្ធទៅនឹងអាជីវកម្ម
- អនុញ្ញាតអោយអ្នកតំណាងនៃសហគមន៍អាជីវកម្មចែករំលែកគំនិតយោបល់ លើទំនួលខុសត្រូវសង្គម (CSR) និងការគោរពសិទ្ធិមនុស្ស។
- ផ្តល់ឱកាសដើម្បីបង្កើតទំនាក់ទំនង រវាងវិស័យឯកជន និងសង្គមស៊ីវិល
- ពិភាក្សាបង្កើត សេចក្តីថ្លែងការណ៏ស្តីពីគោលការណ៏គោរពសិទ្ធិ លើគំរោងអាជីវកម្ម និង សិទ្ធិមនុស្សនៅ ព្រះរាជាណាចក្រកម្ពុជា។

## សិក្ខាសាលានេះត្រូវបានបែងចែកជា ៣ផ្នែកៈ

### ផ្នែក១ — កិច្ចស្វាគមន៍ និង សេចក្តីផ្តើម

លោក គង់ សំអុន, នាយកកម្មវិធី CCHR បានឡើងបើកសិក្ខាសាលា ជាមួយនឹងការបង្ហាញខ្លី១ពី ប្រធាន បទនៃអាជីវកម្ម និង សិទ្ធិមនុស្ស។ គាត់បានសង្កត់ធ្ងន់ថាអាជីវកម្មបានដើរតួនាទីយ៉ាងសំខាន់ក្នុង វិស័យអាជីវកម្ម

និងសិទ្ធិមនុស្ស។ វាអាស្រ័យលើអាជីវកម្មថាតើជាអ្នកការពារ ឬអ្នករំលោភសិទ្ធិមនុស្ស។ គាត់បានពន្យល់ថា អាជីវកម្មអាចប្តេជ្ញាខ្លួនឯង មិនធ្វើការរំលោភសិទ្ធិមនុស្ស ក្នុងប្រតិបត្តិការរបស់ពួកគេ។ ពួកគេអាចយល់ឃើញថា ខ្លួនឯងជាអាជីវកម្មល្អដែលមានគោលការណ៍ និង ច្បាប់ផ្ទៃក្នុង ដែលអនុលោមតាមច្បាប់ សិទ្ធិមនុស្សនានាជាជាងការរំលោភសិទ្ធិមនុស្ស។ គាត់បានបង្ហាញជាទូទៅថា អ្នករាល់គ្នារួមទាំងអាជីវកម្ម ត្រូវតែគោរពសិទ្ធិមនុស្ស និងសំរួលដល់ការប៉ះប៉ូវសង នៅពេលកើតមានការរំលោភសិទ្ធិមនុស្ស។ លោក គង់ សំអុន បានសរុបថា នៅកន្លែងដែលការការពារសិទ្ធិមនុស្សមានការព្រួយបារម្ភ រដ្ឋាភិបាលដែលទទួលខុសត្រូវសំរាប់ការ ការពារនៃសិទ្ធិមនុស្ស ប៉ុន្តែអាជីវកម្មមានទំនួលខុសត្រូវក្នុងការធានាថាសិទ្ធិត្រូវបានគេការពារ និងគោរព។

## ផ្នែក២ — ការពិភាក្សាលើអាជីវកម្មមានការគោរពសិទ្ធិមនុស្សនៅកម្ពុជា

តាមរយៈសិក្ខាសាលាត២គ្នា វាគ្មិនផ្សេង១គ្នាត្រូវបានគេអញ្ជើញមកចែករំលែកបទពិសោធន៍ជាមួយនឹងអ្នកចូលរួមផ្សេង១ ជាមួយនឹងការធ្វើបទបង្ហាញ ២០នាទី។ ដំណើរការនេះអាចអោយអាជីវកម្មដ៏ទៃរៀនពីបទពិសោធន៍ និង តរិយាបទនៃសហគ្រាសរីកចំរើនក្នុងសង្គម។

សិក្ខាសាលានេះមានការចូលរួមដោយ វាគ្មិនចំនួនពីររូបៈ

លោកវង្ស សុវណ្ណ និយាយពីតួនាទីសហជីពក្នុងការពារសិទ្ធិកម្មករ និង ប្រយោជន៍រួមៈ

លោកសុវណ្ណ បានពន្យល់ថា និយោជិកមានសិទ្ធិការពារសិទ្ធិរបស់ខ្លួន និង ជំរុញអោយនិយោជកគោរពសិទ្ធិរបស់ពួកគេ និង ផ្តល់លក្ខខណ្ឌការងារល្អប្រសើរផងដែរ។ និយោជកត្រូវតែយល់ថា កម្មករនិយោជកគឺជាធាតុសំខាន់ក្នុងបន្ទាត់ផលិតកម្ម។ ដូច្នេះនិយោជក ត្រូវតែយកចិត្តទុកដាក់អោយខ្លាំងចំពោះកំលាំងពលកម្ម ដោយសារកម្មករនិយោជិក និង និយោជកដែលមិនអាចខ្វះគ្នាបានឡើយ។ មួយវិញទៀតទាក់ទងនឹងការគោរពសិទ្ធិមនុស្ស គឺការចែករំលែកផលប្រយោជន៍អោយបានសមរម្យ។ យោងទៅតាមការស្រាវជ្រាវរបស់គាត់ ភាគច្រើននៃនិយោជកចង់ចំណាយតិច តែចំណេញច្រើន ដូច្នេះពួកគេចំណាយតិចលើកម្មករ ពួកគេកាន់តែសប្បាយចិត្ត។ ពួកយើងគួរតែកាត់បន្ថយអតុល្យភាពនៃកំលាំងពលកម្ម នៅកន្លែងដែលការចែករំលែកផលប្រយោជន៍ មានការព្រួយបារម្ភ។ និយោជក គួរតែផ្តល់លក្ខខណ្ឌការងារសមរម្យសំរាប់កម្មកររបស់ខ្លួន ពីព្រោះកម្មករ គឺជាកំលាំងពលកម្មរបស់ពួកគេ។ ដោយនិយោជកផ្តល់នូវប្រាក់ឈ្នួលសមរម្យចំពោះកម្មករនិយោជិក ពួកគេកំពុងតែគោរពសិទ្ធិមនុស្សរបស់និយោជិក និង អាចអោយពួកគេរស់នៅដោយផាសុកភាព។ ប្រសិនបើពួកយើងអាចលុបបំបាត់នូវគំលាតនេះ ជម្លោះនឹងបន្ថយដែរ ហើយនិងប្រតិបត្តិការរបស់អាជីវកម្ម ក៏ដំណើរល្អដែរ។ តាមគំនិតរបស់គាត់ និយោជកកម្ពុជាភាគច្រើនមិនគោរពសិទ្ធិមនុស្ស និង ការពារកំលាំងពលកម្មរបស់ពួកគេ។ និយោជកខ្លះជារឿយ១ គិតថាសហជីពគឺជាក្រុមដែលចូលចិត្តបង្ករបញ្ហានៅក្នុងក្រុមហ៊ុន និង រោងចក្រ។ នៅត្រង់ចំនុចនេះ ពួកយើងចង់ផ្លាស់ប្តូរការគិតរបស់ពួកគេ ទៅជាការគិតថាសហជីពជាដៃគូរយ៉ាងល្អនៅក្នុងប្រតិបត្តិការអាជីវកម្ម។ យោងទៅតាមលោក សុវណ្ណ សហជីពអាចដើរតួជាអ្នកផ្តល់ជាយោបល់ និង អាចធ្វើការជាមួយគ្នាក្នុងការចរចារជាមួយម្ចាស់អាជីវកម្ម នៅពេលដែលពួកគេប្រឈមមុខជាមួយនឹងបញ្ហា។ ក្នុងនាមជាម្ចាស់អាជីវកម្ម ពួកគេត្រូវតែចាប់

ផ្ដើមគិតដល់កំលាំងពលកម្មរបស់ពួកគេជាមនុស្ស មិនមែនជាម៉ាស៊ីន ហើយដូច្នេះពួកគេត្រូវតែជៀសវាងពីការបង្ខំពួកគេអោយធ្វើការហួសពីសមត្ថភាពរបស់ពួកគេ។

លោក សុវណ្ណ ថែមទាំងពន្យល់ពី ថាតើសិទ្ធិការងារដើរជាមួយគ្នានឹងការអភិវឌ្ឍន៍សេដ្ឋកិច្ចយ៉ាងដូចម្ដេច។ ពេលជួបវិបត្តិសេដ្ឋកិច្ច សិទ្ធិការងារក៏ធ្លាក់ចុះដែរ ហើរសហជីពប្រឈមមុខនិងការលំបាកជាច្រើន នៅពេលដែលព្យាយាមការពារកម្មករនិយោជិកពីការគាបសង្កត់ និង ភាពអត់ការងារធ្វើ។ មានបញ្ហាជាច្រើនដែលបានកើតឡើងជាលទ្ធផលពីការខ្វះការចរចារ និងពិភាក្សារកដំណោះស្រាយ។ ដែលអាចនាំទៅរកការធ្វើបាតុកម្ម ឬកូដកម្ម។ ការធ្វើបាតុកម្មមិនបានផលប្រយោជន៍ និង ខ្ជះខ្ជាយពេលវេលា និងប្រាក់ចំណេញ។ ការធានាអោយបានពីការគោរពសិទ្ធិមនុស្សនៅកន្លែងធ្វើការ ទាមទារអោយនិយោជក និង កម្មករនិយោជិកយល់ពីសិទ្ធិរបស់ខ្លួន និង គោរពសិទ្ធិគ្នាទៅវិញទៅមក។ លោក សុវណ្ណបញ្ចប់ដោយគូរបញ្ជាក់ថា ការងារដែលមានស្ថេរភាព និង សន្តិភាព អាចកើតឡើងហើយនិងបញ្ហាដែលកើតឡើងតែងតែមានដំណោះស្រាយ។

**លោក យ៉េង វីរៈ ប្រធានមជ្ឈមណ្ឌលអប់រំច្បាប់សំរាប់សហគមន៍ ធ្វើបទបង្ហាញពីលក្ខខណ្ឌការងារសមរម្យនៅកម្ពុជា និង ការប្រឈមរបស់វា**

លោក វីរៈបានបង្ហាញថា បទដ្ឋានអន្តរជាតិ និង ច្បាប់ក្នុងស្រុកសុទ្ធតែនិយាយពីសិទ្ធិមនុស្ស ក៏ដូចជាសិទ្ធិការងារ។ គាត់បានបង្ហាញទៀតថា ពួកយើងទាំងអស់គ្នាសុទ្ធតែមានសិទ្ធិរស់រានមានជីវិត សេរីភាព និងភាពថ្លៃថ្នូរជាមនុស្ស។ សិទ្ធិនេះរាប់ទាំងសិទ្ធិដែលត្រូវទទួលបានការប្រព្រឹត្តជាមួយនឹងភាពជាមនុស្ស ភាពថ្លៃថ្នូរ និងនិតិវិធីច្បាប់ និង ការហាមឃាត់ប្រឆាំងនឹងការសំលាប់និង ការឃុំខ្លួនតាមអំពើចិត្ត ការដាក់ទណ្ឌកម្ម និងការប្រព្រឹត្តឃោឃៅផ្សេងទៀត។ សិទ្ធិស្ត្រីក្នុងការទទួលបានភាពស្មើរគ្នា និង គ្មានការរើសអើងនៅក្នុងន័យសិទ្ធិមនុស្សត្រូវតែបានគេការពារ។ ហើយក៏មានការហាមប្រាមយ៉ាងខ្លាំងដែរលើការរំលោភបំពានផ្លូវភេទ ការប្រើអំពើហឹង្សា និងការកេងប្រវ័ញ្ច។ ច្បាប់អន្តរជាតិការពារសិទ្ធិកម្មករក្នុងការបង្កើតសមាគមន៍ រៀបចំ និងការចរចាររួម និងមានបរិយាកាសការងារប្រកបដោយសុវត្ថិភាព និងសុខភាព។ វាថែមទាំងផ្ដល់នូវការធានាចំពោះប្រាក់ឈ្នួលសំរាប់ការរស់នៅ និង ម៉ោងធ្វើការសមហេតុផល។ សិទ្ធិនេះត្រូវបានគេការពារ ជាពិសេសនៅក្នុងស្ថានភាពដែលគ្រោះថ្នាក់បរិស្ថានប៉ះពាល់ដល់សិទ្ធិផ្សេង រួមមានដល់សិទ្ធិរស់រានមានជីវិត មានសុខភាព ឬសិទ្ធិបុគ្គលផ្ទាល់ខ្លួន។ បន្ថែមទៅលើការការពារទូទៅនៃច្បាប់សិទ្ធិមនុស្ស កុមារក៏មានសិទ្ធិជាក់លាក់ រួមមានសិទ្ធិក្នុងការសំរេចចិត្តដើម្បីជាប្រយោជន៍របស់ពួកគេ។

ម្យ៉ាងវិញទៀត លោក វីរៈក៏និយាយពីតួនាទីនៃសហជីព។ មានពីរហេតុផលក្នុងការបង្កើតសហជីពនៅកន្លែងការងារ។ ទីមួយគឺច្បាប់តំរូវដោយផ្អែកតាមគោលការណ៍សិទ្ធិមនុស្ស និង មួយទៀតគឺថាវាផ្ដល់ប្រយោជន៍សំរាប់ទាំងអស់គ្នា ប្រសិនបើសហជីពនេះត្រូវបានគេបង្កើតឡើងលើគោលការណ៍ជាមូលដ្ឋាននៃប្រយោជន៍រួម។ សហជីព និង និយោជកអាចធ្វើការរួមគ្នា ដោះស្រាយបញ្ហាដែលបានកើតឡើង ដូច្នេះអាចកាត់បន្ថយនូវហានិភ័យនៃការធ្វើការកូដកម្ម ឬបាតុកម្មដែលមិនមានប្រយោជន៍ដល់អាជីវកម្មទេ។ និយោជក និង កម្មករត្រូវតែយល់សិទ្ធិ

របស់ខ្លួន។ លោក វីរៈបានលើកឡើងចំនុចដែលសំខាន់ជាងនេះទៀតគឺ ពួកគេមិនត្រូវរំលោភសិទ្ធិផ្សេងៗទេ ដើម្បីលុបបំបាត់នូវជម្លោះនៅកន្លែងការងារ។ ទោះជាយ៉ាងនេះក្តី ប្រសិនបើភាគីទាំងពីរប្រឈមមុខនឹងបញ្ហា ពួកគេត្រូវតែអង្គុយនិង ពិភាក្សា។ ប្រសិនបើពួកគេមិនធ្វើដូច្នេះទេ វាធ្វើអោយបញ្ហាកាន់តែធំ។ ដូច្នេះ សហជីពដើរតួនាទីយ៉ាងសំខាន់ក្នុងការសម្របសម្រួល លើកឡើងជាបញ្ហា និងធ្វើការចចារជាមួយនិយោជក។សហជីពអាចជួយអោយដំណើរការអាជីវកម្មដំណើរល្អ។

ចំពោះព័តិមានបន្ថែមៈ

- អនុសញ្ញា ៨៧ ស្តីពីសេរីភាពនៃការបង្កើតសមាគមន៍ ឬសហជីព និង ការការពារសិទ្ធិក្នុងការបង្កើតអនុសញ្ញានេះ ១៩៤៨ៈ កម្មករនិយោជិកអាចចូលរួមជាមួយសហជីព ដែលឯករាជ្យពីរដ្ឋាភិបាល និងឥទ្ធិពលពីនិយោជក និង អនុសញ្ញា ៩៨ ស្តីពីសិទ្ធិបង្កើត និង ការចចាររួម ១៩៤៩ៈ កម្មករនិយោជិកអាចធ្វើការចចារជាមួយនឹងនិយោជករួមគ្នា ប្រឆាំងនឹងបុគ្គល។
- ការហាមប្រាមរាល់ទំរង់នៃការងារដោយបង្ខំ (អនុសញ្ញា ២៩ស្តីពីការងារដោយបង្ខំ ១៩៣០)ៈ រួមមានសុវត្ថិភាពពីការងារដូចគុក និងទាសភាព ហើយការងារកម្មករនិយោជិកពីការត្រូវបានគេបង្ខំអោយធ្វើការក្រោមការបង្ខិតបង្ខំ។
- ការលុបបំបាត់ចោលរាល់ទំរង់នៃពលកម្មកុមារៈ ការអនុវត្តអាយុអប្បបរមាក្នុងការធ្វើការងារ (អនុសញ្ញា ១៣៨ ស្តីពីអាយុអប្បបរមាធ្វើការងារ ១៩៧៣) និង តំរូវការនៃលក្ខខណ្ឌធ្វើការងារសំរាប់កុមារ
- ការលុបបំបាត់ការរើសអើងនៅកន្លែងការងារ (អនុសញ្ញា ១០០ និង ១១១ ស្តីពីការទទួលបានប្រាក់ឈ្នួលស្មើគ្នាចំពោះបុរស និងស្ត្រី សំរាប់ការងារមានតំលៃដូចគ្នា ១៩៥១ និង គ្មានការរើសអើង ១៩៥៨
- មាត្រា ២៣ នៃសេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិៈ

  **១**.មនុស្សគ្រប់រូប មានសិទ្ធិធ្វើការងារ ជ្រើសរើសការងារដោយសេរី និងធ្វើការងារក្នុងលក្ខខណ្ឌត្រឹមត្រូវ និង ពេញចិត្ត ព្រមទាំងការពារប្រឆាំងនឹងភាពអត់ការងារធ្វើ។

  **២**.មនុស្សគ្រប់រូប មានសិទ្ធិទទួលប្រាក់បៀវត្សស្មើគ្នាចំពោះការងារដូចគ្នា ដោយគ្មានការរើសអើង។

  **៣**.អ្នកធ្វើការងារ មានសិទ្ធិទទួលបានលាភការដោយសមធមិនិងពេញចិត្ត ដើម្បីធានាអត្ថិភាពរស់នៅរបស់ខ្លួន និងគ្រួសារ អោយសមស្របនឹងសេចក្តីថ្លៃថ្នូរនៃមនុស្ស និង ត្រូវបានបំពេញបន្ថែមទៀតតាមមធ្យោបាយផ្សេងៗនៃការការពារផ្នែកសង្គម ប្រសិនបើចាំបាច់។

  **៤**.មនុស្សគ្រប់រូប មានសិទ្ធិបង្កើត និងចូលរួមសហជីព ដើម្បីការពារផលប្រយោជន៍របស់ខ្លួន។

**សំនួរ និង ចំលើយៈ**

ក្នុងផ្នែក ២នៃសិក្ខាសាលា សំនួរ និង ចំលើយត្រូវបានគេលើកឡើងៈ

១. លោក ចក់ សុភីៈ សូមជួយបញ្ជាក់ពីអនុសញ្ញារួម រវាងសហជីព និង និយោជក?

- លោក វង្ស សុវណ្ណៈ ការធ្វើអនុសញ្ញារួម គឺផ្អែកលើសហជីពដែលមានចំនួនសមាជិកគ្រប់គ្រាន់ ដើម្បីចុះបញ្ជីរនៅក្រសួងការងារ បន្ទាប់មកដាក់សំណើរដើម្បីចចារជាមួយនិង និយោជក។ អនុសញ្ញារួមនេះល្អជាងច្បាប់និងអនុសញ្ញាផ្សេងៗ។ មានន័យថា វាមកបំពេញចន្លោះនៃច្បាប់ និង អនុសញ្ញានោះ។ ការធ្វើអនុសញ្ញារួមអាចត្រូវបានគេធ្វើឡើង ជារៀងពីរឆ្នាំម្តង ដើម្បីធានាថា វាអាចប្រើប្រាស់បានគ្រប់ទិដ្ឋភាពទាំងអស់នៃអាជីវកម្ម។

**ផ្នែកទី៣---ការពិភាក្សាលើសេចក្តីថ្លែងការណ៍ស្តីពីគោលការណ៍គោរពសិទ្ធិនៃគំរោងអាជីវកម្ម និង សិទ្ធិមនុស្សៈ**

លោកគង់ សំអុនចាប់ផ្តើមដោយពន្យល់ថា SOP គឺផ្អែកលើគោលការណ៍សិទ្ធិមនុស្សដែលមានចែងក្នុងច្បាប់ជាតិ និង អន្តរជាតិ គឺមិនមែនជាចំណង និង មិនជាកាតព្វកិច្ចបង្ខំលើក្រុមហ៊ុនដែលចុះហត្ថលេខាទេ។ SOP ដូចជាឯកសារសំអាងមួយចំពោះក្រុមហ៊ុនដែលត្រូវបានគេអំពាវនាវ ដើម្បីធានាថាក្រុមហ៊ុនប្រកាន់ភ្ជាប់ទៅនឹងសិទ្ធិមនុស្ស។ ជាងនេះទៅទៀត SOP អាចត្រូវបានប្រើប្រាស់ដោយក្រុមហ៊ុនដើម្បីបង្ហាញពីការប្តេជ្ញាក្នុងការការពារ និង គោរពសិទ្ធិមនុស្ស ដែលជួយអោយពួកគេកសាងទំនាក់ទំនងល្អជាមួយនឹងបុគ្គលិករបស់ពួកគេ។

ការពិភាក្សានេះប្រព្រឹត្តទៅបានយ៉ាងល្អ។ ដោយមានការផ្តល់ជាយោបល់ដោយភាគីអ្នកចូលរួម ពាក្យពេចន៏ដែលប្រើប្រាស់ក្នុង SOP មានការផ្លាស់ប្តូរដែលកាន់តែងាយស្រួលយល់ និង កាន់តែមានអត្ថន័យ។ មានសំនួរជាច្រើនត្រូវបានគេសួរដើម្បីបង្ហាញបញ្ជាក់នូវចំនុចមួយចំនួននៅក្នុងគោលការណ៍ SOP។ ចុងបញ្ចប់នៃការពិភាក្សា អ្នកចូលរួមទាំងអស់មានការយល់ព្រមជាមួយនឹង SOP នេះ។ ពួកគេទាំងអស់បង្ហាញពីគោលបំណងក្នុងការចុះហត្ថលេខាលើ SOP នៅសិក្ខាសាលាដ៏ធំខាងមុខ។

**ផ្នែកទី ៤---បិទកម្មវិធី**

លោកគង់ សំអុនឡើងបិទសិក្ខាសាលា ដោយអរគុណចំពោះអ្នកចូលរួមចំពោះ ការចំណាយពេលក្នុងការចូលរួមនៅក្នុងសិក្ខាសាលានេះ។ គាត់បង្ហាញថា ការពិភាក្សានៃ SOP ដំណើរការល្អដោយសារមានការចូលរួមរបស់ពួកគេ។ គាត់សង្ឃឹមថា សិក្ខាសាលា និង លទ្ធផលនៃការពិភាក្សា នឹងមានប្រយោជន៏សំរាប់អ្នកជំនាន់ក្រោយ។ លោកគង់ សំអុនបានបិទកម្មវិធីដោយរំលឹកអ្នកចូលរួមថា សិក្ខាសាលាដ៏ធំរបស់គំរោងនេះនឹងធ្វើឡើងនៅថ្ងៃទី ១១ មិថុនា នៅសណ្ឋាគារ កាំបូឌីយ៉ាណា និង ផ្តោតសំខាន់លើ SOP។

***សង្ខេបៈ***

អ្វីដែលសិក្ខាសាលានេះសំរេចបានមានៈ

- ការយល់នៃអ្វីដែលជាសិទ្ធិមនុស្ស និង វិធីដែលពួកគេមានការពាក់ព័ន្ធនឹងអាជីវកម្ម
- វិស័យឯកជន សហជីព និង បណ្តាញ NGOs គឺត្រូវបានគេបង្កើតឡើង និង កាន់តែមានច្រើនជាសមាជិកពីវិស័យនិមួយៗអោយកាន់តែស្គាល់គ្នា។
- SOP ត្រូវបានគេបង្កើតឡើង។

**<u>បើក និង បិទកម្មវិធីដោយៈ</u>**

លោក គង់ សំអុន——នាយកកម្មវិធី CCHR

**<u>វាគ្មិន និងអ្នករៀបចំៈ</u>**

លោក វង្ស សុវណ្ណ--ប្រធាន CWLFU

លោក យ៉េង វីរៈ——ប្រធាន CLEC

លោក ចក់ សុភី——អ្នកសម្របសម្រួលគំរោង CCHR

កញ្ញា ឃុន កែវមុនី — មន្ត្រីគំរោង CCHR

Bijan Hoshi — អ្នកហាត់ការ CCHR

លោក លាង ផាន់ណារ៉ា — អ្នកហាត់ការ CCHR